អនុក្រឹត្យស្ដីពីមគ្គុទ្ទេសក៍ទេសចរណ៍នេះ នឹងអនុវត្តចំពោះមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់នៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដែលមានតួនាទីភារកិច្ចជាអាជ្ញាកណ្ដាលផ្សារភ្ជាប់ទំនាក់ទំនងរវាងរាជរដ្ឋាភិបាល និងភ្ញៀវទេសចរ។ ទន្ទឹមនឹងនេះមគ្គុទ្ទេសក៍ទេសចរណ៍ក៏ជាអ្នកនាំពាក្យ បកស្រាយនូវរាល់តថៈភាពសង្គម ជាមួយនឹងការធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ និងសេដ្ឋកិច្ចសង្គម នៃទីកន្លែងទស្សនានីមួយៗជូនដល់ភ្ញៀវទេសចរផងដែរ។

អាស្រ័យដោយមគ្គុទ្ទេសក៍ទេសចរណ៍ដើរតួនាទីដ៏ចម្បង ជាកម្លាំងចលករដ៏មានសក្ដានុពល និងមានសារៈសំខាន់ដល់សេដ្ឋកិច្ចសង្គម តាមរយៈការបង្កើតការងារ បង្កើនប្រាក់ចំណូល កាត់បន្ថយភាពក្រីក្រ និងលើកស្ទួយនូវខឿនប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់... របស់ជាតិ ដូចនេះការដាក់ចេញនូវបញ្ញត្តិកម្ម អនុក្រឹត្យស្ដីពីមគ្គុទ្ទេសក៍ទេសចរណ៍នេះ គឺជាឧបករណ៍មួយពុំអាចខ្វះបានក្នុងការតម្រែតម្រង់ទិស គ្រប់គ្រង ត្រួតពិនិត្យ ចូលរួមជំរុញឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់យកចិត្តទុកដាក់គោរពឲ្យបានខ្ជាប់ខ្ជួននូវក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ ធានាបាននូវការលើកកំពស់កិត្យានុភាពជាតិលើឆាកអន្តរជាតិ និងរួមចំណែកដល់កិច្ចអភិវឌ្ឍវិស័យទេសចរណ៍ប្រកបដោយនិរន្តរភាព។

ដើម្បីជាមូលដ្ឋានក្នុងការប្រៀបធៀបទៅនឹងបញ្ញត្តិកម្មខាងលើ ក្រុមការងារវាយតំលៃផលប៉ះពាល់លិខិតបទដ្ឋានគតិយុត្តិយើងខ្ញុំបានដាក់ចេញនូវជម្រើសមួយទៀត គឺ **ប្រកាស ស្ដីពីការបង្កើតក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ (ជាជម្រើសទី២)។**

ជម្រើសទី២នេះ គឺជាការបង្កើតឡើងត្រឹមតែក្រុមការងារមួយ ដែលមានតួនាទីចុះត្រួតពិនិត្យ វាយតំលៃ តាមដាននូវរាល់សកម្មភាពរបស់មគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់នៅទូទាំងប្រទេស ពិសេសនៅតាមគោលដៅទេសចរណ៍នីមួយៗ ព្រមជាមួយនឹងការរៀបចំផ្ដល់ជារង្វាន់ បណ្ណសរសើរ ដល់មគ្គុទ្ទេសក៍ទេសចរណ៍ណាដែលមានស្នាដៃល្អប្រសើ។ សកម្មភាពនេះទាមទារនូវចំនួនមន្ត្រីរាជការច្រើនបង្គួរ ការធ្វើសកម្មភាពជាប់ជាប្រចាំ ជាមួយនឹងកញ្ចប់ថវិកាជាមធ្យមមួយចំនួន។

ក្រោយពីធ្វើការសិក្សា វិភាគទៅតាមចំណុចទាំង៧ របស់RIA ក្រុមការងារពិនិត្យឃើញថាថ្វីបើជម្រើសទី២នេះមានបន្ទុកចំណាយតិចជាងសំណើបញ្ញត្តិកម្មក៏ដោយ ប៉ុន្តែបើយើងធ្វើការវិភាគឲ្យបានស៊ីជម្រៅ គឺជម្រើសទី២នេះហាក់ផ្ដល់នូវផលប្រយោជន៍សង្គមទាបជាង បើប្រៀបធៀបទៅនឹងសំណើបញ្ញត្តិកម្ម។

ហេតុនេះសំណើបញ្ញត្តិកម្ម «អនុក្រឹត្យស្ដីពីមគ្គុទ្ទេសក៍ទេសចរណ៍» អាចនឹងផ្ដល់ផលប្រយោជន៍សង្គមដ៏ធំធេងបំផុត តាមរយៈការចូលរួមក្នុងការបង្កើតការងារ កាត់បន្ថយការចំណាកស្រុក លើកកំពស់ជីវភាពប្រជាពលរដ្ឋ លើកកំពស់ស្ត្រី ផ្ដល់នូវសមភាពយេនឌ័រក្នុងសង្គម។ ជាពិសេសគឺចូលរួមជំរុញឲ្យមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់យល់កាន់តែច្បាស់អំពីតួនាទីភារកិច្ច និងបង្កើននូវមោទនភាពរបស់ខ្លួនដែលមានឱកាសអាចទំនាក់ទំនងជាមួយនឹងភ្ញៀវគ្រប់ជាតិសាសន៍លើពិភពលោក។ ដូច្នេះមគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ត្រូវចូលរួមគោរពច្បាប់របស់រដ្ឋ និងរាល់លិខិតបទដ្ឋានគតិយុត្តិទេសចរណ៍ដើម្បីចូលរួមជំរុញឲ្យប្រទេសកម្ពុជាក្លាយទៅជានីតិរដ្ឋ ប្រកបដោយសន្ទុះរីកចម្រើនជឿនលឿនទាន់អារ្យប្រទេសនានាលើសកលលោក។

# របាយការណ៍ស្ដីពីវាយតម្លៃបឋម

## អនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍

## ក្រសួងទេសចរណ៍

លេខយោង: ........

កាលបរិច្ឆេទចាប់ផ្តើម: ថ្ងៃ២០ ខែឧសភា ឆ្នាំ ២០១៤

កាលបរិច្ឆេទបញ្ចប់ : ថ្ងៃ២០ ខែឧសភា ឆ្នាំ ២០១៥

ទំនាក់ទំនង:

| | ឈ្មោះ | លេខទូរស័ព្ទ | អ៊ីមែល |
|---|---|---|---|
| IA-ដឹកនាំ | លោក កើត ពុទ្ធវរី | ០១៧ ៩៣៨ ៨៨៧ | puthvory@yahoo.com |
| IA-ទទួលបន្ទុក | លោក ជួន ជ័យសត្យា | ០៨៩ ៦៨៩ ៨៩៨ | sathia.chuon@gmail.com |
| IA-សមាជិក | លោក ជុក ជំនោរ | ០៨១ ៨៨៨ ៨៧៧ | chumno_chuk@yahoo.com |
| IA-សមាជិក | លោក ធី រដ្ឋា | ០៧០ ៨៧ ៨៧ ៥០ | rotha_thy89@yahoo.com |
| IA-ជំនួយការ | លោក យ៉ន សុខុម | ០៩៧ ៧៧៧ ៨១២៥ | yansokhom2015@gmail.com |
| IA-ជំនួយការ | លោកស្រី សុខ សុជាតា | ០១១ ៩៥ ៩៦ ៨៦ | socheatasok91@gmail.com |
| IA-ជំនួយការ | ក.មូល លីតា | ០៦៩ ៦២ ៣៣ ២០ | moullyta@gmail.com |
| ORIA - អនុប្រធាន | លោក ឡោ ប៉ូលីណា | ០១២ ៧៨៨ ៦០៦ | polinalor@yahoo.com |
| ORIA-ទទួលបន្ទុក | លោក ហេង សុភ:បញ្ញា | ០១៦ ៨៨៧ ៧៨៩ | pangha.h@gmail.com |
| ORIA-ជំនួស | លោក សំ សំណាង | ០៧៧ ៦៤ ៨០ ៩៥ | somnangs001@gmail.com |

**អត្ថាធិប្បាយសង្ខេបអំពីសំណើបញ្ញត្តិកម្ម**

| |
|---|
| បញ្ញាត្តិកម្មនេះ មានគោលដៅកំណត់វិធានគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍នៅកម្ពុជាប្រកបដោយប្រសិទ្ធភាពនិងគុណភាព ដើម្បីជំរុញវិស័យទេសចរណ៍ និងរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ចជាតិ។ មគ្គុទ្ទេសក៍ទេសចរណ៍មានតួនាទីភារៈកិច្ច និងប្រកបអាជីពជាអ្នកទទួលជូនថៃរក្សាភ្ញៀវជាតិ អន្តរជាតិ និងធ្វើអត្ថាធិប្បាយពន្យល់អំពីភូមិសាស្ត្រ ធម្មជាតិ ប្រវត្តិសាស្ត្រ វប្បធម៌ ប្រពៃណី សិល្បៈ ទំនៀមទម្លាប់ និងសេដ្ឋកិច្ចសង្គម នៃទីកន្លែងទស្សនាជូនដល់ភ្ញៀវទេសចរ។ មគ្គុទ្ទេសក៍ទេសចរណ៍ជាអ្នកនាំពាក្យ ជាសេនាធិការ ជាអាជ្ញាកណ្តាលក្នុងការផ្សារភ្ជាប់រវាង ប្រជាជនកម្ពុជាជាមួយនឹងភ្ញៀវទេសចរ ដូច្នេះមគ្គុទ្ទេសក៍ទេសចរណ៍ពិតជាមានតួនាទីដ៏ចម្បង ជាកម្លាំងចលករដ៏មានសក្តានុពល និងមានសារៈសំខាន់ដល់ខឿនសេដ្ឋកិច្ចសង្គម តាមរយៈការបង្កើតការងារ បង្កើនប្រាក់ចំណូល និងកាត់បន្ថយភាពក្រីក្រ។ |

**ប្រភេទបញ្ញត្តិកម្ម**

| ច្បាប់ | ព្រះរាជក្រឹត្យ | អនុក្រឹត្យ | ប្រកាស | សេចក្តីសម្រេច | សារាចរ | ផ្សេងទៀត |
|---|---|---|---|---|---|---|
| ☐ | ☐ | ☑ | ☐ | ☐ | ☐ | ☐ |

តើសំណើនេះមានចរិកជាបញ្ញត្តិកម្ម ហើយវាមានផលប៉ះពាល់ដល់ធុរកិច្ចដែរឬទេ?

☑**មែន**/ ☐**មិនមែន**

## ១. ភារកំណត់បញ្ហា

| **បញ្ហាសំខាន់ៗ** | **បញ្ញត្តិកម្មនេះមានបំណងដោះស្រាយ** *(គូស✓មែនឬមិនមែន)* | **ភស្តុតាង/ភាពជាក់ស្តែង (សូមភ្ជាប់កំណត់សម្គាល់ប្រសិនបើចាំបាច់)** |
|---|---|---|
| សុខភាពនិងសុវត្ថិភាពសាធារណៈ | ☑មិនមែន | |
| ការការពារ និងអភិរក្សបរិស្ថាន | ☑មិនមែន | |
| សមធម៌យេនឌ័រ | ☑មែន | មគ្គុទ្ទេសក៍ទេសចរណ៍ បានឆ្លងកាត់វគ្គបណ្តុះ -បណ្តាលពីប្រវត្តិសាស្ត្រ និងវប្បធម៌ ដូច្នេះតួនាទី |

| | | |
|---|---|---|
| សង្គម<br><br>និងការអភិរក្សវប្បធម៌ | | ពួកគាត់ត្រូវផ្សព្វផ្សាយ និងបកស្រាយពន្យល់ដល់ទេសចរអំពីរឿងរ៉ាវប្រវត្តិសាស្ត្រ និង វប្បធម៌ប្រពៃណីបានត្រឹមត្រូវពិតប្រាកដ សច្ចៈធម៌ ជៀសវាងការនិយាយបកស្រាយខុសៈ<br><br>• មគ្គុទ្ទេសក៍ទេសចរណ៍មួយចំនួនជានារីដែលជាឱកាសផ្តល់ការងារឲ្យនារីមានសិទ្ធិដូចបុរស<br><br>• កាត់បន្ថយចំណាកស្រុក<br><br>• មានចំណេះដឹងច្បាស់លាស់ផ្នែកវប្បធម៌ ប្រវត្តិសាស្ត្រ..... របស់ជាតិ |
| ការប្រកួតប្រជែង | ☑មិនមែន | |
| ការប្រមូលព័ត៌មាន | ☑មែន | ជារៀងរាល់ឆ្នាំ មគ្គុទ្ទេសក៍ទេសចរណ៍ត្រូវចូលរួមវគ្គបណ្តុះបណ្តាលបំប៉នដើម្បីបង្កើនចំណេះដឹងថ្មីៗ មគ្គុទ្ទេសក៍ទេសចរណ៍មានតួនាទីក្នុងការប្រមូលព័ត៌មានពីជុំវិញពិភពលោកពីសំណាក់ទេសចរ យកមកផ្សព្វផ្សាយយ៉ាងទូលំទូលាយនៅក្នុងប្រទេស និងផ្តល់ជូនដល់ទេសចរវិញនូវព័ត៌មានប្រកបដោយសច្ចៈភាពរបស់ប្រទេសខ្លួន។បច្ចុប្បន្នយើងមានមគ្គុទ្ទេសក៍ប្រមាណ ៩០៤៩ នាក់ (នៅឆ្នាំ២០១៤ ទេសចរណ៍ចំនួន ៤,២លាននាក់ ហើយតាមផែនការយុទ្ធសាស្ត្រជាតិ ទេសចរណ៍នឹងកើនដល់ចំនួន ៨លាននាក់នៅឆ្នាំ២០២០)។ |
| អនុលោមតាមកិច្ចព្រមព្រៀងWTO និងកិច្ចព្រមព្រៀងអន្តរជាតិផ្សេងទៀត | ☑មិនមែន | |

*ប្រសិនបើមានបញ្ហាផ្សេងទៀតសូមអធិប្បាយនិងផ្តល់ភស្តុតាង*

**កន្លងមកមានមគ្គុទ្ទេសក៍ទេសចរណ៍មួយចំនួនតូច**បានប្រព្រឹត្តអំពើមិនគប្បីប្រាសចាកក្រមសីលធម៌ ដូចជា ការនាំភ្ញៀវទិញទំនិញក្លែងក្លាយ ណែនាំភ្ញៀវទៅរកសេវាកម្មផ្លូវភេទ និងគ្រឿងញៀន និងមិនគោរពតួនាទីពេលប្រតិបត្តិការងាររបស់ខ្លួន។
**ឧ១៖** ករណីភ្ញៀវទេសចរជនជាតិហ្វីលីពីន ត្រូវបានមគ្គុទ្ទេសក៍ទេសចរណ៍ នាំទៅទិញគ្រឿង អលង្ការក្លែងក្លាយដែលមានតំលៃជាង ៣ម៉ឺនដុល្លាអាមេរិច ក្នុងខេត្តសៀមរាប។
**ឧ២៖** ស្វែងរកសេវាកម្មផ្លូវភេទសម្រាប់ភ្ញៀវទេសចរ ពេលខ្លះស្វែងរកកុមារក្រោមអាយុ ១៨ឆ្នាំទៀត។
**ឧ៣៖** មគ្គុទ្ទេសក៍ទេសចរណ៍មួយចំនួនតូចបានប្រើប្រាស់អាជ្ញាបណ្ណក្លែងក្លាយ ឬហួសសុពលភាព ស្វែងរកកំរៃជើងសារ និងមិនដែលបានចូលរួមទប់ស្កាត់ ប្រឆាំងនឹងសកម្មភាពទាក់ទងជាមួយនិងការជួញដូរផ្លូវភេទ កុមារ និងគ្រឿងញៀន ។ល។

**សូមរាយបញ្ជីលិខិតបទដ្ឋានគតិយុត្តដែលមានស្រាប់ដែលពាក់ព័ន្ធឬប្រហាក់ប្រហែល។**

១. ច្បាប់ស្តីពីទេសចរណ៍ ឆ្នាំ២០០៩
២. ប្រកាសស្តីពីក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍

**ចូរបញ្ជាក់ថាតើហេតុអ្វីបានជាលិខិតបទដ្ឋានគតិយុត្តទាំងនេះមិនទាន់គ្រប់គ្រាន់?**

ច្បាប់ស្តីពីទេសចរណ៍ បានចែងតែលើគោលការណ៍ទូទៅនៃវិស័យទេសចរណ៍ ដោយមិនបានចែងលំអិតពីវិធានគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ តួនាទីភារកិច្ច កាតព្វកិច្ចរបស់មគ្គុទ្ទេសក៍ទេសចរណ៍ក្នុងការផ្តល់សេវាកម្មដ៏ល្អប្រសើរ ប្រកបដោយគុណភាពដល់ភ្ញៀវទេសចរឡើយ។

ចំពោះប្រកាសស្តីពីក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌វិជ្ជាជីវៈមគ្គុទ្ទេសក៍ទេសចរណ៍ក៏ពុំសូវសង្កត់ធ្ងន់និងមានខ្លឹមសារស៊ីជម្រៅដល់ការងារជំរុញនិងគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ផងដែរ។

**តើយើងពិតជាចាំបាច់ត្រូវរកជម្រើសផ្សេងទៀតដែរឬទេ?** ☑មែន

## ២. គោលបំណង -

លើកកម្ពស់គុណភាព សេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ ប្រកបដោយក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌ឲ្យបានល្អប្រសើរ ធានាឲ្យបាននូវសេចក្តីពេញចិត្ត និងទំនុកចិត្តពីសំណាក់ភ្ញៀវទេសចរជាតិ និងអន្តរជាតិ និងដើម្បីចូលរួមចំណែកសម្រេចឲ្យបាននូវការទាក់ទាញចំនួនភ្ញៀវទេសចរអន្តរជាតិប្រមាណ ៨លាននាក់ក្នុងឆ្នាំ ២០២០ឲ្យមកទស្សនាកម្ពុជា។

### ៣. ជម្រើស -

៣.ក. ជម្រើសផ្សេងៗដែលអាចអនុវត្តបាន (សម្រាប់ការវិភាគលើផលប៉ះពាល់)

| |
|---|
| ១. អនុក្រឹត្យស្ដីពីមគ្គុទ្ទេសក៍ទេសចរណ៍<br>២. ប្រកាសស្ដីពីការបង្កើតក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ |

## ៤. ការប៉ាន់ស្មានបឋមលើចំណាយភាគពួកកិច្ច

៤.១. ការកំណត់ភារកិច្ច និងប្រភេទចំណាយ(tasks and cost-categories)

| ជម្រើស | រាជរដ្ឋាភិបាល | ធុរកិច្ច |
|---|---|---|
| **ជម្រើសទី១:** អនុក្រឹត្យស្ដីពីមគ្គុទ្ទេសក៍ទេសចរណ៍ | ○ ចំណាយរៀបចំសេចក្ដីព្រាងបញ្ញត្តិកម្ម<br>○ ចំណាយរៀបចំពិគ្រោះយោបល់ និងសិក្ខាសាលា<br>○ បោះពុម្ពឯកសារផ្សព្វផ្សាយ<br>○ ចំណាយលើការងាររដ្ឋបាល<br>○ ធ្វើអធិការកិច្ចត្រួតពិនិត្យលើសកម្មភាពមគ្គុទ្ទេសក៍ទេសចរណ៍ | ○ ចូលរួមកិច្ចប្រជុំពិគ្រោះយោបល់ និងសិក្ខាសាលា<br>○ ចំណាយលើការបណ្ដុះបណ្ដាល<br>○ ចំណាយលើអាជ្ញាបណ្ណ (២ឆ្នាំម្ដង)<br>○ ចំណាយលើឯកសណ្ឋាន |
| **ជម្រើសទី២:ប្រកាស ស្ដីពីការបង្កើតក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍** | ○ ផ្ដល់ប្រាក់ឧបត្ថម្ភសម្រាប់មន្ត្រីបុគ្គលិកលើកិច្ចការងារបន្ថែម<br>○ បង្កើតសូចនករសម្រាប់ផ្ដល់បណ្ណសរសើរ<br>○ ចុះវាយតំលៃរៀបចំផ្ដល់ ចំណាត់ថ្នាក់<br>○ បង្កើត និងផលិតចំណាត់ថ្នាក់ និងរង្វាន់<br>○ ចំណាយរៀបចំពិធីផ្ដល់រង្វាន់ចំណាត់ថ្នាក់ | ○ ចុះឈ្មោះនិងបំពេញសំណុំឯកសារផ្សេងៗ (របាយការណ៍...)<br>○ ចូលរួមប្រជុំ និងចូលរួមវគ្គបណ្ដុះបណ្ដាលបំប៉ន<br>○ ចូលរួមក្នុងកម្មវិធីចែកចំណាត់ថ្នាក់រង្វាន់ |

៤.២. វិសាលភាពនៃជម្រើសនីមួយៗ

| ជម្រើស | វិស័យឬប្រភេទធុរកិច្ច | ចំនួនធុរកិច្ច | ឯកសារយោង/ភស្តុតាង |
|---|---|---|---|
| ជម្រើសទី១: អនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ | គ្រប់មគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ | ៤០៤៩ | របាយការណ៍បូកសរុបការងារប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍ឆ្នាំ ២០១៣<br>និងទិសដៅអនុវត្តបន្ត |
| ជម្រើសទី២:ប្រកាស ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ទេសចរណ៍ | គ្រប់មគ្គុទ្ទេសក៍ទេសចរណ៍ទាំងអស់ | ៤០៤៩ | របាយការណ៍បូកសរុបការងារប្រចាំឆ្នាំរបស់ក្រសួងទេសចរណ៍ឆ្នាំ ២០១៣ |

៤.៣. ប៉ាន់ស្មានចំណាយបន្ថែមរបស់ធុរកិច្ចនិងរាជរដ្ឋាភិបាល

| ធុរកិច្ច | | |
|---|---|---|
| ជម្រើស | កំណើនចំណាយ<br>អនុលោមតាមបញ្ញត្តិកម្ម | ផ្តល់អំណះអំណាង |
| ជម្រើសទី១: | ☑មិនគួរឲ្យកត់សម្គាល់ | បន្ទុកចំណាយរបស់ធុរកិច្ចគឺ ៤,៦០៨,៩៣៨ ដុល្លារ ក្នុងចំណោមធុរៈកិច្ច ៤០៤៩ ជាមធ្យមធុរៈកិច្ចនីមួយៗចំណាយតែ ១១៣៨ដុល្លាប៉ុណ្ណោះ |
| ជម្រើសទី២: | ☑មិនគួរឲ្យកត់សម្គាល់ | បន្ទុកចំណាយរបស់ធុរកិច្ចគឺ ១០០ដុល្លារ ក្នុងមគ្គុទ្ទេសក៍ម្នាក់ ក្នុងចំណោមធុរៈកិច្ច ៤០៤៩មគ្គុទ្ទេសក៍ទេសចរណ៍។ |
| | | |

| រាជរដ្ឋាភិបាល | | |
|---|---|---|
| ជម្រើស | កំណើនចំណាយ<br>អនុលោមតាមបញ្ញត្តិកម្ម | ផ្តល់អំណះអំណាង |
| ជម្រើសទី១: | ☑មិនគួរឲ្យកត់សម្គាល់ | បន្ទុកចំណាយសរុប ៣៦,៩៥៦ ដុល្លា មិនគួរឲ្យកត់សំគាល់បើ ប្រៀបធៀបជាមួយប្រាក់ចំណូលប្រចាំឆ្នាំ នៃក្រសួងទេសចរណ៍ ទទួលបានពីមគ្គុទ្ទេសក៍-ទេសចរណ៍ដែលមានរហូតទៅដល់ ២៥២,៩៥០ដុល្លាក្នុងមួយឆ្នាំ។<br>ក្រៅពីចំណូលផ្ទាល់មានចំណូលមិនផ្ទាល់ដែលរួមចំណែកយ៉ាងធំធេងដល់វិស័យសេដ្ឋកិច្ច សង្គម។ |
| ជម្រើសទី២ : | ☑ គួរឲ្យកត់សម្គាល់ | បន្ទុកចំណាយសរុប ១៨១,០៦០ ដុល្លា ស្មើនឹង៧០%បើប្រៀបធៀបជាមួយប្រាក់ចំណូលពីអាជ្ញាប័ណ្ណមគ្គុទ្ទេសក៍ទេសចរណ៍ប្រចាំឆ្នាំរបស់ក្រសួងដែលមានចំនួន២៥២,៩៥០ដុល្លា។ |

៥.៥. ប៉ាន់ស្មានកម្រិតនៃផលចំណេញ

| ជម្រើស | ផលចំណេញ | ផ្តល់អំណះអំណាង |
|---|---|---|
| ជម្រើសទី១: | ☑គួរឲ្យកត់សម្គាល់ | ១. បង្កើនគុណភាពនៃសេវាកម្មតាមរយៈការគោរព និងប្រតិបត្តិនូវក្រមសីលធម៌វិជ្ជាជីវៈ។<br>២. ជម្រុញការអនុវត្តច្បាប់នៅកម្ពុជាក្នុងវិស័យទេសចរណ៍<br>៣. អាចទាក់ទាញភ្ញៀវទេសចរ និងផ្តល់ទំនុកចិត្តក្នុងការមកទស្សនាប្រទេសកម្ពុជាឲ្យកាន់តែច្រើន។ |

| | | |
|---|---|---|
| | | ៤. ដើម្បីជំរុញការលើកទឹកចិត្ត ទីផ្សារសេវាកម្មទេសចរណ៍ និងបង្កើនគុភាពមគ្គុទ្ទេសក៍ទេសចរណ៍ ជូនភ្ញៀវទេសចរ។<br>៥.បង្កើនធម្មារម្មណ៍របស់ភ្ញៀវទេសចរ និងកសាងនូវកិត្តិនាមនៃប្រទេសកម្ពុជាលើឆាកទេសចរណ៍អន្តរជាតិ។ |
| **ជម្រើសទី២ :** | ☑ មិនគួរឲ្យកត់សម្គាល់ | ដោយសារផលចំណេញតិចជាងជម្រើសទីមួយ។ |

**៤.៥. តើសំណើបញ្ញត្តិកម្មមានផលប៉ះពាល់អវិជ្ជមានដល់ការប្រកួតប្រជែងដែរឬទេ?**

**☑មិនគួរឲ្យកត់សម្គាល់**

**៤.៦.តើសំណើបញ្ញត្តិកម្មនេះមានផលប៉ះពាល់អវិជ្ជមានលើសមធម៌យេនឌ័រដែរឬទេ?**

| |
|---|
| បញ្ញត្តិកម្មនេះមិនមានផលប៉ះពាល់ដល់សមធម៌យេនឌ័រនោះទេ !!! |

## ៥. កិច្ចពិគ្រោះយោបល់

កិច្ចពិគ្រោះយោបល់នេះមានគោលបំណងធ្វើឲ្យចំណុចខាងលើកាន់តែប្រសើរឡើង។កិច្ចពិគ្រោះយោបល់ជាមួយសំណាក(Sample)នៃអ្នកពាក់ព័ន្ធ។ សូមធ្វើជារបៀបការប្រជុំប្រមូលគំនិត(brainstorming session) ឬការពិគ្រោះយោបល់ជាក្រុមជំនាញ(focus group interviews)។ កិច្ចពិគ្រោះយោបល់លម្អិតអាចធ្វើឡើងតាមក្រោយប្រសិនបើតម្រូវឲ្យមានរបាយការណ៍ RIS។

| **ក្រុមអ្នកពាក់ព័ន្ធ** | | **វិធីសាស្ត្រ** | **សង្ខេបទស្សនៈ** |
|---|---|---|---|
| ធុរកិច្ច | សមាគមធុរកិច្ច (តំណាងឲ្យ% នៃវិស័យធុរកិច្ច) | ឧ.ជាលាយលក្ខណ៍អក្សរកិច្ចប្រជុំ/ ទូរស័ព្ទ<br>-ចុះសាកសួរព័ត៌មានផ្ទាល់មាត់<br>-ធ្វើសម្ភាសន៍<br>-សាកសួរតាមរយៈ | -គាំទ្រឲ្យមានអនុក្រឹត្យមគ្គុទ្ទេសក៍និងជំរុញការអនុវត្តឲ្យបានខ្លាំងក្លា។<br>-ឯកភាព១០០%ក្នុងការដាក់ចេញនូវបទបញ្ញត្តិអនុក្រឹត្យមគ្គុទ្ទេសក៍នេះព្រោះផ្តល់នូវផលប្រយោជន៍ធំធេងដល់ការពង្រឹងគុណភាពសេវាកម្ម។ |

| | | | |
|---|---|---|---|
| | | បណ្ណព័ត៌មាន<br>-ទីភ្នាក់ងារទេសចរណ៍<br>-អាជីវករ<br>-សេវាទេសចរណ៍<br>-មគ្គុទ្ទេសក៍ផ្ទាល់ | |
| | | | |
| អ្នកប្រើប្រាស់ | ក្រុមអ្នកប្រើប្រាស់ | | |
| | អ្នកប្រើប្រាស់ចម្បងៗ (អ្នកប្រើប្រាស់ទំនិញ/សេវាកម្មអ្វីមួយក្នុងបរិមាណច្រើន) | -ភ្ញៀវទេសចរណ៍បរទេស<br>-ភ្ញៀវទេសចរណ៍ក្នុងស្រុក | -សុំឲ្យក្រសួងទេសចរណ៍ជំរុញការអនុវត្តឲ្យបានសកម្មមានប្រសិទ្ធិភាព។<br>-មានការត្រួតពិនិត្យជាប់ជាប្រចាំ។<br>-សុំឲ្យមានការសហការពីគ្រប់ភាគីដែលពាក់ពន្ធ័ក្នុងការចុះត្រួតពិនិត្យ។<br>-មគ្គុទ្ទេសក៍ខ្លួនឯងផ្ទាល់ត្រូវចូលរួមលើកកំពស់ការអនុវត្ត និងទទួលខុសត្រូវ ព្រមទាំងមានការភ្ញាក់រលឹកក្នុងការអនុវត្តខ្លឹមសារអនុក្រឹត្យ អោយស្របទៅតាមក្រមសីលធម៌។មិនត្រូវពាក់ពន្ធ័ទៅនឹងគ្រឿងញៀន ទេសចរណ៍ផ្លូវភេទ កំរៃជើងសារ ។ល។<br>-ស្នើសុំលុបបំបាត់ការបន្លំការដើរតួជាមគ្គុទ្ទេសក៍របស់ជនបរទេស ។<br>-ស្នើអោយក្រសួងទេសចរណ៍ រៀបចំតួនាទីភារកិច្ច របស់មគ្គុទ្ទេសក៍ទាំង៥ប្រភេទឲ្យបាន |

| | | | |
|---|---|---|---|
| | | | ច្បាស់លាស់ ដើម្បីជៀសវាងការជាន់តួនាទីគ្នានាំឲ្យមគ្គុទ្ទេសក៍ បាត់បង់ការងារ ។<br>-បណ្តុះបណ្តាលមគ្គុទ្ទេសក៍បន្ថែមឲ្យបានច្រើនភាសាជានាទាំងគុណភាពនិងបរិមាណ ។<br>-ជំរុញការគ្រប់គ្រងតាមប្រព័ន្ធ Internet ។ |
| | អ្នកប្រើប្រាស់តូចៗ(អ្នកប្រើប្រាស់ទំនិញ/សេវាកម្មអ្វីមួយក្នុងបរិមាណតិចតួច)។ | -ប្រជាពលរដ្ឋដែលពាក់ពន្ធ័ក្នុងវិស័យទេសចរណ៍ | |

## ៦.សន្និដ្ឋាន

៦.១. សេចក្តីសង្ខេបនៃចំណាយកាតព្វកិច្ចបន្ថែមនិងផលចំណេញ

| ជម្រើស | ចំណាយរបស់ធុរកិច្ច | ចំណាយរបស់រាជរដ្ឋាភិបាល | ផលចំណេញ |
|---|---|---|---|
| ជម្រើសទី១: អនុក្រឹត្យស្តីពីមគ្គុទ្ទេសក៍ទេសចរណ៍ | មិនគួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ |
| ជម្រើសទី២: បង្កើក្រុមការងារវាយតម្លៃ ផ្តល់រង្វាន់លើកទឹកចិត្តរៀបចំធ្វើចំណាត់ថ្នាក់មគ្គុទ្ទេសក៍ទេសចរណ៍ | មិនគួរឲ្យកត់សម្គាល់ | គួរឲ្យកត់សម្គាល់ | មិនគួរឲ្យកត់សម្គាល់ |

៦.២. តើចាំបាច់ធ្វើRIS ដែរឬទេ?

☑ មិនចាំបាច់- *សូមផ្តល់អំណះអំណាងនិងបំពេញការវាយតម្លៃបឋម(PAS) ដែលនៅសេសសល់។*

| |
|---|
| មិនចាំបាច់ធ្វើRISដោយសារផលប៉ះពាល់ទៅលើមគ្គុទ្ទេសក៍ចរណ៍ម្នាក់ៗមានទំហំតិចតួច (១១៣៨ដុល្លាក្នុងមួយនាក់មិនមែន សម្រាប់មួយឆ្នាំទេគ្រាន់ទេជាការចំណាយលើកដំបូង) សំណើនេះមិនមានបន្ទុកចំណាយធ្ងន់ធ្ងរដល់មគ្គុទ្ទេសក៍ទេ។ |

## ៦.៣. ជម្រើសដែលបានជ្រើសរើស

| |
|---|
| គួរជ្រើសរើសជម្រើសទី១ ពីព្រោះតាមការវិភាគខាងលើបង្ហាញថាជម្រើសទី១ នេះនឹងផ្តល់ចំណេញខ្ពស់ជាងជម្រើសទី២ ដោយជួយលើកកម្ពស់គុណភាព សេវាកម្មមគ្គុទ្ទេសក៍ទេសចរណ៍ ប្រកបដោយក្រមប្រតិបត្តិវិជ្ជាជីវៈ និងក្រមសីលធម៌ ឲ្យបានល្អប្រសើរ និងមានការទទួលស្គាល់ពីភ្ញៀវទេសចរជាតិ និងអន្តរជាតិ ជាពិសេសការមានទំនុកចិត្ត ការចូលរួមថែរក្សា ការពារនូវវប្បធម៌ជាតិ ព្រមទាំងរួមចំណែកយ៉ាងធំធេងដល់ការនាំមកនូវប្រាក់ចំណូលប្រយោលជូនដល់សង្គមជាតិថែមទៀត។ |

| លក្ខណវិនិច្ឆ័យ | | មូលហេតុ |
|---|---|---|
| តើវាជាជម្រើសដែលមានចំណាយកាតព្វកិច្ចបន្ថែមអប្បបរមាសម្រាប់វិស័យធុរកិច្ចនិង សហគមន៍ដែរឬទេ? | មែន | មគ្គុទ្ទេសក៍ទេសចរណ៍ នីមួយៗចំណាយត្រឹមតែ ១១៣៨ដុល្លារដែលជាការចំណាយលើដំបូលប៉ុណ្ណោះ។ |
| តើជម្រើសនេះផ្តល់នូវផលចំណេញអតិបរមាដែរឬទេ? | មែន | -ជម្រើសនេះផ្តល់នូវផលប្រយោជន៍ធំធេងដល់ការពង្រឹងគុណភាពសេវាកម្ម ប្រកបដោយវិជ្ជាជីវៈអាចទាក់ទាញភ្ញៀវទេសចរឲ្យមកទស្សនាកម្ពុជាកាន់តែច្រើនឡើង ដែលជាប្រភពចំណូលយ៉ាងសំខាន់ដល់សេដ្ឋកិច្ចជាតិនិងចូលរួមផ្សព្វផ្សាយកម្ពុជាព្រះរាជាណាចក្រអច្ឆរិយៈ និងចលនាប្រឡងប្រណាំងទីក្រុងស្អាត រមណីយដ្ឋានស្អាត សេវាល្អ។ |

## ៧. ការអនុវត្តនិងការតាមដាន

១. បង្កើតក្រុមការងារគ្រប់គ្រង តាមដាន ត្រួតពិនិត្យ វាយតម្លៃមគ្គុទ្ទេសក៍

ក្រសួងទេសចរណ៍ត្រូវរៀបចំកិច្ចប្រជុំ និងបង្កើតក្រុមការងារគ្រប់គ្រងមគ្គុទ្ទេសក៍ ក្នុងការអនុវត្តទៅលើការអនុវត្តរបស់មគ្គុទ្ទេសក៍ ក៏ដូចជាការត្រួតពិនិត្យតាមដាននិងវាយតម្លៃ ប្រកបដោយស្មារតីទទួលខុសត្រូវ ព្រោះវាជាផលប្រយោជន៍ផ្ទាល់របស់ខ្លួន និងជាកិត្យានុភាពរបស់ប្រទេសជាតិ។

២. អនុក្រឹត្យនេះគួរត្រូវបានធ្វើការត្រួតពិនិត្យ កែសម្រួលឡើងវិញឲ្យសមស្របទៅនឹងការអភិវឌ្ឍរបស់វិស័យទេសចរណ៍ក្នុងរយៈពេល ៥ឆ្នាំ។

| ដំណើរការ | ឈ្មោះ | មុខងារ | ហត្ថលេខា | កាលបរិច្ឆេទ |
|---|---|---|---|---|
| រៀបចំដោយ<br>(ក្រសួងពាក់ព័ន្ធ) | | | | |
| ត្រួតពិនិត្យដោយ<br>(ORIA) | | | | |
| | | | | |
| | | | | |
| ឯកភាពដោយ<br>(ORIA) | | | | |
| បញ្ចូលទិន្នន័យ<br>ដោយ | | | | |
| បញ្ចូលក្នុងគេហទំព័រដោយ | | | | |